ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៩០ . អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣០ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីកាតព្វកិច្ចយោធា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨-ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើក្រមព្រហ្មទណ្ឌ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២០០ អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្ដីពីលក្ខខណ្ឌនិងបែបបទនៃការធ្វើជំរឿន ការជ្រើសរើស ការអញ្ជើញ ការពន្យារពេលសម្រាប់យុវជនកំពុង[illegible] ប្រជាពលរដ្ឋដែលស្ថិតក្នុងករណីពិសេស និងការអនុវត្តច្បាប់ស្ដីពីកាតព្វកិច្ចយោធា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី០៥ ខែ[illegible]

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងគ្រប់គ្រងលើការបញ្ជូនពលករខ្មែរ ទៅធ្វើការនៅបរទេស។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅដូចតទៅ៖

- រកទីផ្សារការងារនិងផ្តល់ការងារជូនប្រជាពលរដ្ឋខ្មែរទៅធ្វើការនៅបរទេស
- លើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋខ្មែរ
- ធានាសុវត្ថិភាពជូនពលករខ្មែរដែលទៅធ្វើការនៅបរទេស
- រួមចំណែកលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស
- រួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការកាត់បន្ថយភាពក្រីក្រ។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើបេក្ខជនពលករទេសន្តរប្រវេសន៍ ពលករខ្មែរ និងទីភ្នាក់ងារជ្រើសរើសទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤.-**

ពាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចតទៅ៖

- បេក្ខជនពលករទេសន្តរប្រវេសន៍ សំដៅដល់ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានអាយុចាប់ពី១៨ឆ្នាំឡើង ដែលបានដាក់ពាក្យសុំទៅធ្វើការនៅបរទេសនិងកំពុងបំពេញបែបបទជាផ្លូវការតាមរយៈទីភ្នាក់ងារជ្រើសរើសស្របតាមគោលការណ៍របស់ស្ថាប័នមានសមត្ថកិច្ចដែលមានជាអាទិ៍ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងមហាផ្ទៃ។
- ពលករ សំដៅដល់ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលស្ថិតនៅគ្រប់ដំណាក់កាលទេសន្តរប្រវេសន៍ការងារ ចាប់ពីពេលចុះកិច្ចសន្យាសេវាកម្មការងារឲ្យធ្វើជាមួយទីភ្នាក់ងារជ្រើសរើសរហូតដល់ពេលធ្វើមាតុភូមិនិវត្តន៍។ ទន្ទឹមនឹងនេះ ក៏រាប់បញ្ចូលប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលទៅធ្វើកម្មសិក្សាផងនិងធ្វើការងារផងនៅបរទេស ហើយមានកិច្ចសន្យាត្រឹមត្រូវដែលទទួលស្គាល់ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។
- សេវាកម្មការងារឲ្យធ្វើ សំដៅដល់សេវាកម្មការងារឲ្យធ្វើដោយពេញលេញនៅប្រទេសណាមួយ ក្រៅពីព្រះរាជាណាចក្រកម្ពុជាស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារនិងច្បាប់ជាធរមាននានានៃព្រះរាជាណាចក្រកម្ពុជានិងប្រទេសទទួលពលករ

- ទីភ្នាក់ងារជ្រើសរើស សំដៅដល់និតិបុគ្គលឯកជនដែលត្រូវបានបង្កើតឡើងត្រឹមត្រូវតាមច្បាប់និងបទបញ្ញាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានអនុញ្ញាតជាផ្លូវការដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈឲ្យទទួលខុសត្រូវក្នុងការផ្តល់សេវាកការងារឲ្យធ្វើដោយពេញលេញនៅបរទេស។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា ៥.-**

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាក្រសួងមានសមត្ថកិច្ចក្នុងការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសដោយធ្វើកិច្ចសហការជាមួយនឹងក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ និងក្រសួងមហាផ្ទៃ។

## ជំពូកទី៣
## ទីភ្នាក់ងារជ្រើសរើស

**មាត្រា ៦.-**

ទីភ្នាក់ងារជ្រើសរើសពលករខ្មែរទៅធ្វើការនៅបរទេស ត្រូវទទួលបានការអនុញ្ញាតតាមប្រកាសរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈដោយឥតបង់ថ្លៃ លើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះ។

របៀបបទក្នុងការអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ទីភ្នាក់ងារជ្រើសរើស ត្រូវគោរពច្បាប់និងបទប្បញ្ញត្តិជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៧.-**

ដើម្បីទទួលបានការអនុញ្ញាត ទីភ្នាក់ងារជ្រើសរើសត្រូវបំពេញលក្ខខណ្ឌចាំបាច់មួយចំនួនដូចខាងក្រោម៖

ក- ត្រូវមានទីចាត់ការដែលមានអាសយដ្ឋានច្បាស់លាស់ មានបុគ្គលិកបម្រើការងារ សម្ភារៈការិយាល័យ មធ្យោបាយទំនាក់ទំនង និងមធ្យោបាយដឹកជញ្ជូនគ្រប់គ្រាន់។

ខ- ត្រូវមានមជ្ឈមណ្ឌលណែនាំតម្រង់ទិសដែលមានទំហំសមស្រប៖

- អគារដែលបំពាក់ដោយឧបករណ៍និងសម្ភារៈសម្រាប់ការងារបំប៉នមុខជំនាញនិងភាសាស្របតាមបទដ្ឋានមុខជំនាញនិងតម្រូវការទីផ្សារការងារ និងសម្រាប់ការងារអប់រំណែនាំតម្រង់ទិសមុនពេលចេញដំណើរតាមគោលការណ៍កំណត់
- កន្លែងស្នាក់នៅហូបចុកដែលត្រឹមត្រូវនិងធានាបាននូវសុខភាពអនាម័យល្អ

សុវត្ថិភាពល្អ
- បទបញ្ជាផ្ទៃក្នុងរបស់ខ្លួនដែលទទួលស្គាល់ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

គ- ត្រូវមានគ្រូសម្រាប់ការបំប៉នមុខជំនាញភាសាស្របតាមបទដ្ឋានមុខជំនាញនិងតម្រូវការរបស់អ្នកទទួលពលករ។

ឃ- ត្រូវចុះកិច្ចសន្យាជាមួយនឹងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈអំពីភាតព្វកិច្ចនិងនីតិវិធីនៃការប្រតិបត្តិសេវាកម្មការងារឲ្យធ្វើ។

ង- ត្រូវតម្កល់ប្រាក់ធានាត្រឹមត្រូវតាមគោលការណ៍ណែនាំដូចមានចែងក្នុងមាត្រា៨និងមាត្រា១០នៃអនុក្រឹត្យនេះ។

ច- ត្រូវមានតំណាងអចិន្ត្រៃយ៍នៅប្រទេសដែលទទួលពលករ។

**មាត្រា ៨.-**

ក្រោយពីទទួលបានការអនុញ្ញាតតាមប្រកាសរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃយ៉ាងយូរ ទីភ្នាក់ងារជ្រើសរើសត្រូវតម្កល់ប្រាក់ធានាជាប្រាក់រៀលដែលមានចំនួនសមមូលនឹង១០០ ០០០(មួយសែន)ដុល្លារអាមេរិក នៅក្នុងគណនីរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈដែលស្ថិតនៅក្នុងធនាគារណាមួយ។ ឯកសារឲ្យប់ដើមនៃការតម្កល់ប្រាក់ធានានេះ ត្រូវយកទៅតម្កល់ទុកនៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ៩.-**

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវចាត់ឲ្យមានការធ្វើអធិការកិច្ចសាមញ្ញនិងអធិការកិច្ចពិសេសចំពោះទីភ្នាក់ងារជ្រើសរើស។

## ជំពូកទី៤
## ការប្រើប្រាស់ប្រាក់ធានា

**មាត្រា ១០.-**

ប្រាក់ធានាដែលបានតម្កល់នៅក្នុងគណនីរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចត្រូវបានដកយកមកប្រើប្រាស់ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ចាត់ចែងដោះស្រាយចំពោះករណីសំខាន់ៗមួយចំនួន៖

ក- ចំពោះករណីប្រធានសក្តិ សង្គ្រាម កលិយុគ ជំងឺរាតត្បាត នៅក្នុងប្រទេសទទួលពលករឬនៅកន្លែងពលករធ្វើការដែលចាំបាច់ត្រូវចល័តពលករទៅរកទីកន្លែងដែលមានសុវត្ថិភាពឬបញ្ជូនពលករមកកាន់មាតុភូមិវិញ ដើម្បីធានាសុវត្ថិភាព ប្រាក់ធានាដែលត្រូវបានដកយកមកប្រើប្រាស់ត្រូវបានបំពេញដោយថវិកាជាតិឬដោយប្រភពជំនួយសង្គ្រោះណាមួយ។

ខ- ចំពោះករណីដែលទីភ្នាក់ងារជ្រើសរើសមិនបានគោរពលក្ខខណ្ឌនៃកិច្ច

រវាងទីភ្នាក់ងារជ្រើសរើសនិងពលករ ឬរវាងទីភ្នាក់ងារជ្រើសរើសនិងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយមិនព្រមដោះស្រាយតាមគោលការណ៍សម្របសម្រួល ហេតុប៉ះពាល់ដល់ផលប្រយោជន៍របស់ពលករ ប្រាក់ធានាដែលត្រូវបានដកយកមកប្រើប្រាស់ ត្រូវបានបំពេញឲ្យគ្រប់ចំនួនឡើងវិញ ដោយទីភ្នាក់ងារជ្រើសរើសក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃយ៉ាងយូរ។

**មាត្រា ១១.-**

ទីភ្នាក់ងារជ្រើសរើសអាចស្នើសុំដកប្រាក់ធានាមកវិញបានក្នុងករណីបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ទីភ្នាក់ងារជ្រើសរើសបានបញ្ឈប់ជាស្ថាពរនូវការជ្រើសរើសនិងការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស
- ពលករដែលបានបញ្ជូនទៅធ្វើការនៅបរទេស បានត្រឡប់មកមាតុភូមិវិញអស់ហើយ
- ទីភ្នាក់ងារជ្រើសរើសបានដោះស្រាយបញ្ហាជាមួយពលករចប់សព្វគ្រប់។

## ជំពូកទី៥
## ទីផ្សារការងារនិងជំនាញពលករ

**មាត្រា ១២.-**

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវស្វែងរកនិងផ្តល់ការគាំទ្រ លើកទឹកចិត្តក្នុងការស្វែងរកទីផ្សារការងារល្អៗនៅបរទេស សម្រាប់បង្កឱកាសការងារជូនពលរដ្ឋខ្មែរ។

**មាត្រា ១៣.-**

ទីភ្នាក់ងារជ្រើសរើសត្រូវធ្វើកិច្ចសហការជាមួយនឹងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិក្នុងការពិនិត្យ សិក្សាស្រាវជ្រាវអំពីតម្រូវការកម្លាំងពលកម្មនិងជំនាញការងារ ដើម្បីបង្កឱកាសការងារសម្រាប់ប្រជាពលរដ្ឋខ្មែរ។

**មាត្រា ១៤.-**

ក្នុងលទ្ធភាពសមស្រប ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវធ្វើកិច្ចសហការជាមួយនឹងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិដើម្បីរៀបចំកិច្ចព្រមព្រៀង ឬអនុស្សរណៈនៃការយោគយល់គ្នារវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងប្រទេសទទួលពលករ ស្តីពីការប្រើប្រាស់កម្លាំងពលកម្ម។

## ជំពូកទី៦
## កិច្ចសន្យា

**មាត្រា ១៥.-**

ក្នុងការជ្រើសរើសនិងការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស ទីភ្នាក់ងារជ្រើសរើសត្រូវចុះកិច្ចសន្យានិងអនុវត្តកិច្ចសន្យាឲ្យបានត្រឹមត្រូវ។

កិច្ចសន្យាចាំបាច់មួយចំនួនរួមមាន៖

- កិច្ចសន្យារវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនិងទីភ្នាក់ងារជ្រើសរើស

- កិច្ចសន្យារវាងទីភ្នាក់ងារជ្រើសរើសនិងពលករខ្មែរ ដែលមានឈ្មោះថាកិច្ចសន្យាសេវាកម្មការងារឲ្យធ្វើ
- កិច្ចសន្យារវាងនិយោជកបរទេសនិងពលករខ្មែរ ដែលមានឈ្មោះថាកិច្ចសន្យាការងារ។

កិច្ចសន្យាការងារត្រូវបញ្ជាក់ឲ្យបានច្បាស់ជាអាទិ៍ អំពីលក្ខខណ្ឌការងារ ស្ថានភាពការងារ ប្រភេទការងារ ផលប្រយោជន៍ដែលទទួលបាន និងអាសយដ្ឋានសំខាន់ៗដែលត្រូវធ្វើការទំនាក់ទំនង។

**មាត្រា ១៦.-**

កិច្ចសន្យារវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនិងទីភ្នាក់ងារជ្រើសរើស និងកិច្ចសន្យាសេវាកម្មការងារឲ្យធ្វើ ត្រូវធ្វើជាភាសាខ្មែរ ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ១៧.-**

កិច្ចសន្យាការងារត្រូវធ្វើជាភាសាខ្មែរ ភាសាប្រទេសទទួលពលករ និងភាសាអង់គ្លេស ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃប្រទេសទទួលពលករ។

កិច្ចសន្យាទាំងនេះត្រូវបញ្ជូនទៅស្ថានឯកអគ្គរាជទូតឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសទទួលពលករ តាមរយៈក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា ១៨.-**

គំរូកិច្ចសន្យាដែលមានចែងក្នុងមាត្រា១៥នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

កិច្ចសន្យានេះត្រូវមានហត្ថលេខារបស់អ្នកតំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ជំពូកទី៧
## ការជ្រើសរើសពលករនិងការណែនាំតម្រង់ទិសមុនចេញដំណើរ

**មាត្រា ១៩.-**

ទីភ្នាក់ងារជ្រើសរើស ត្រូវទទួលខុសត្រូវលើបែបបទនានានិងការពិនិត្យសុខភាពពលករខ្មែរដែលត្រូវចេញទៅធ្វើការនៅបរទេស ស្របតាមការកំណត់របស់ប្រទេសទទួលពលករ។

ពលករខ្មែរដែលបញ្ជូនទៅធ្វើការនៅបរទេសមិនអាចគេចផុតពីកាតព្វកិច្ចបង់ពន្ធដារឡើយ។

## ជំពូកទី៨
## ការធ្វើមាតុភូមិនិវត្តន៍របស់ពលករ

**មាត្រា ២៦.-**

នៅពេលដែលកិច្ចសន្យាការងាររបស់ពលករ ឈានដល់ទីបញ្ចប់ ហើយពលករមិនបានបន្តកិច្ចសន្យាទៀតទេ ទីភ្នាក់ងារជ្រើសរើស ត្រូវរៀបចំដំណើរការមាតុភូមិនិវត្តន៍របស់ពលករនោះឲ្យបានត្រឹមត្រូវតាមការកំណត់ ដោយត្រូវជូនដំណឹងជាផ្លូវការទៅស្ថានឯកអគ្គរាជទូតឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសទទួលពលករ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងរយៈពេលយ៉ាងតិច៣០( សាមសិប )ថ្ងៃនៃថ្ងៃធ្វើការ មុនការធ្វើមាតុភូមិនិវត្តន៍មួយលើកៗ ដោយបញ្ជាក់ឲ្យច្បាស់អំពីចំនួនឈ្មោះពលករ ពេលវេលា និងច្រកទ្វារព្រំដែនដែលពលករត្រូវឆ្លងកាត់។

**មាត្រា ២៧.-**

ទីភ្នាក់ងារជ្រើសរើស ត្រូវផ្តល់សេវាសមស្រប ដើម្បីធានាឲ្យពលករបានវិលត្រឡប់មកដល់ព្រះរាជាណាចក្រកម្ពុជាប្រកបដោយសុវត្ថិភាព។

**មាត្រា ២៨.-**

នៅពេលមកដល់ព្រះរាជាណាចក្រកម្ពុជា ទីភ្នាក់ងារជ្រើសរើស ត្រូវបញ្ជូនពលករទាំងអស់ទៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីទទួលលិខិតបញ្ជាក់អំពីការងារដែលពលករបានអនុវត្តនៅបរទេស និងយកទៅប្រើប្រាស់តាមលទ្ធភាពដែលអាចប្រើបាន។

## ជំពូកទី៩
## ការដោះស្រាយវិវាទ

**មាត្រា ២៩.-**

វិវាទដែលកើតឡើងរវាងទីភ្នាក់ងារជ្រើសរើសនិងពលករមុនពេលពលករចេញទៅធ្វើការនៅបរទេស ត្រូវដោះស្រាយតាមច្បាប់ស្តីពីការងារនិងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣០.-**

ចំពោះវិវាទដែលកើតឡើងរវាងនិយោជកបរទេសនិងពលករដែលកំពុងធ្វើការនៅបរទេស ទីភ្នាក់ងារជ្រើសរើសនិងស្ថានឯកអគ្គរាជទូតឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសដែលទទួលពលករ ត្រូវចូលរួមដោះស្រាយ។

ក្នុងករណីចាំបាច់ដែលត្រូវមានមន្ត្រីជំនាញរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈចូលរួមឬកមេធាវីដើម្បីការពារក្តីរបស់ពលករ រាល់ការចំណាយជាបន្ទុករបស់ទីភ្នាក់ងារជ្រើសរើស។

## ជំពូកទី១០
## ការបាត់ខ្លួនពលករ

**មាត្រា ៣១.-**

ក្នុងករណីមានការបាត់ខ្លួនពលករនៅក្នុងរយៈពេលអនុវត្តកិច្ចសន្យាសេវាកការងារឲ្យធ្វើ ទីភ្នាក់ងារជ្រើសរើសត្រូវផ្តល់ព័ត៌មានជាបន្ទាន់ដល់អាជ្ញាធរមានសមត្ថកិច្ច ក្រសួងមហាផ្ទៃនិងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ៣២.-**

នៅពេលទទួលបានព័ត៌មានស្តីពីការបាត់ខ្លួនពលករនៅក្នុងរយៈពេលអនុវត្តកិច្ចសន្យាការងារ ទីភ្នាក់ងារជ្រើសរើសត្រូវផ្តល់ព័ត៌មានជាបន្ទាន់ដល់ស្ថានឯកអគ្គរាជទូតឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសទទួលពលករ ក្រសួងមហាផ្ទៃ និងក្រសួងការងារនិងបណ្តុះបណ្តាល វិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី១១
## របបសន្តិសុខសង្គម

**មាត្រា ៣៣.-**

ទីភ្នាក់ងារជ្រើសរើស ត្រូវទទួលបន្ទុករៀបចំនិងធានាថា ពលករដែលត្រូវបានបញ្ជូនទៅធ្វើការនៅបរទេស ទទួលបានរបបសន្តិសុខសង្គមស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃប្រទេសទទួលពលករ។

**មាត្រា ៣៤.-**

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវត្រួតពិនិត្យតាមដានការអនុវត្តរបស់ទីភ្នាក់ងារជ្រើសរើសលើការទទួលបាននូវរបបសន្តិសុខសង្គមរបស់ពលករ ព្រមទាំងធ្វើកិច្ចសហប្រតិបត្តិការជាមួយប្រទេសទទួលពលករ។

## ជំពូកទី១២
## ប្រាក់បញ្ញើរបស់ពលករមកកម្ពុជា

**មាត្រា ៣៥.-**

ទីភ្នាក់ងារជ្រើសរើសត្រូវជួយពលករដែលទៅធ្វើការនៅបរទេសក្នុងការបើកនិងការប្រើគណនីផ្ទាល់ខ្លួននៅក្នុងធនាគារណាមួយដែលមានសុវត្ថិភាព ដើម្បីបង្កលក្ខណៈឲ្យពលកររក្សាទុកប្រាក់និងផ្ញើមកក្រុមគ្រួសារនៅកម្ពុជាតាមប្រព័ន្ធធនាគារ។

**មាត្រា ៣៦.-**

ក្នុងករណីចាំបាច់ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវជួយសម្រួល[illegible]ក្នុងការបើកគណនីនៅធនាគារណាមួយ ដើម្បីផ្ទេរប្រាក់ពីបរទេស។

## ជំពូកទី១៣
## ការលើកសរសើរ

**មាត្រា ៣៧._**

ទីភ្នាក់ងារជ្រើសរើសណាដែលដំណើរការជ្រើសរើសនិងបញ្ជូនពលករទៅធ្វើការនៅបរទេសបានល្អប្រសើរ ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលបាននូវការលើកសរសើរ ស្របទៅតាមកម្រិតនីមួយៗ។

**មាត្រា ៣៨._**

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវផ្តល់បណ្ណសរសើរដល់ទីភ្នាក់ងារជ្រើសរើសដែលអនុវត្តកិច្ចសន្យាបានល្អ។

## ជំពូកទី១៤
## ទណ្ឌកម្ម

**មាត្រា ៣៩._**

ទីភ្នាក់ងារជ្រើសរើសណាដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មដូចតទៅ៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការព្យួរការអនុញ្ញាតជាបណ្តោះអាសន្ន
- ការដកការអនុញ្ញាតជាស្ថាពរ។

**មាត្រា ៤០._**

ទីភ្នាក់ងារជ្រើសរើសឬជនទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ឬច្បាប់ជាធរមាន ឬប្រើប្រាស់មុខងារនិងសមត្ថកិច្ចរបស់ខ្លួនបង្កជាឧបសគ្គ មិនសមស្រប ចំពោះសកម្មភាពជ្រើសរើសនិងបញ្ជូនពលករទៅធ្វើការនៅបរទេសដោយខុសច្បាប់ត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី១៥
## អវសានប្បញ្ញត្តិ

**មាត្រា ៤១._**

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវចេញសារាចរណែនាំអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព។

**មាត្រា ៤២._**

អនុក្រឹត្យលេខ៥៧ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៤៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ឆ្នាំ២០១១

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្ដឹង

១ .នាងខ្ញុំឈ្មោះ អែម នឿន អាយុ២២ឆ្នាំ ជនជាតិខ្មែរ ប្រើប្រាស់ទូរស័ព្ទលេខ ០៨៧ ៧៨ ៦៧ ៥១
២. ខ្ញុំបាទឈ្មោះ សឿន ចាន់នី អាយុ ២២ឆ្នាំ ជនជាតិខ្មែរ ប្រើប្រាស់ទូរស័ព្ទលេខ ០៩៦ ៨ ៤៩៨ ៩៣២
៣. ខ្ញុំបាទឈ្មោះ អែម សំណាង អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ ប្រើប្រាស់ទូរស័ព្ទលេខ ០៦៩ ៧២៤ ២៧៦

បច្ចុប្បន្នស្នាក់នៅភូមិត្រពាំងព្រីង សង្កាត់ឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ ។

សូមគោរពចូលមក

**ឯកឧត្តម ឧត្តមសេនីយ៍ឯក ប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ**

**កម្មវត្ថុ ៖** សុំប្ដឹង នាយកក្រុមហ៊ុន ទើ ប្រេស៊ីឌិន តេលេហ្គោ (THE PRESIDENT TELEGO COMPANY) និងអ្នកតំណាងក្រុមហ៊ុន ឈ្មោះ សុ នីតា ភេទស្រី អាយុប្រហែល ២១ឆ្នាំ, ឈ្មោះ ឈិញ ភេទស្រី អាយុប្រហែល ២២ឆ្នាំ និងឈ្មោះ ឃែ ភេទស្រី អាយុប្រហែល ២២ឆ្នាំ មានទីតាំងស្ថិតនៅផ្ទះលេខ ០១AE (បុរីឡាយគង់) ជាន់ទី០១ កងទី០៣ ផ្លូវលេខ០១ ឡូតិ៍ ៣០០២១ ភូមិសំបួរ សង្កាត់ជង្គោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ព្រមទាំង ម្ចាស់ទូរស័ព្ទលេខ ០៩៦ ៥ ៩៧៤ ៩៧៨ / ០៨៨ ៣ ០៩៩ ០៨៨ ។

ពីបទៈ ឆបោក ។

តបតាមកម្មវត្ថុខាងលើ សូមគោរព ជម្រាបជូន **ឯកឧត្តម ឧត្តមសេនីយ៍ឯក** មេត្តាជ្រាបថា ៖

យើងខ្ញុំកើតទុក្ខមិនសុខចិត្ត ចំពោះព្រឹត្តការណ៍កាលពីថ្ងៃទី២១ ខែមេសា ឆ្នាំ ២០១៧ ត្រង់ចំនុច ក្រុមហ៊ុន ទើ ប្រេស៊ីឌិន តេលេហ្គោ ទីតាំងស្ថិតនៅ បុរីឡាយគង់ ភូមិសំបួរ សង្កាត់ជង្គោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ចំពោះអំពើរបស់ នាយកក្រុមហ៊ុន ទើ ប្រេស៊ីឌិន តេលេហ្គោ (THE PRESIDENT TELEGO COMPANY) និងអ្នកតំណាងក្រុមហ៊ុន ឈ្មោះ សុ នីតា, ឈ្មោះ ឈិញ និងឈ្មោះ ឃែ ដែលបានប្រព្រឹត្តមកលើយើងខ្ញុំ ដោយបាន មកធានាអះអាងថា អាចជួយយើងខ្ញុំទៅធ្វើការនៅប្រទេសជប៉ុនបាន បន្ទាប់ពីបង់ប្រាក់ចុះឈ្មោះ និងបានធ្វើលិខិតឆ្លងដែនហើយ រយៈពេល ១ខែ នឹងបញ្ជូនយើងខ្ញុំទៅធ្វើការនៅប្រទេសជប៉ុន ។ ដោយមានការជឿទុកចិត្តយើងខ្ញុំក៏បាន ប្រគល់ប្រាក់ឱ្យតំណាងក្រុមហ៊ុនទាំងបីនាក់ខាងលើ ក្នុងម្នាក់ៗចំនួន ៨០ដុល្លារ ។ លុះមកដល់ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០១៧ តំណាងក្រុមហ៊ុន ប្រើទូរស័ព្ទលេខ ០៩៦ ៥ ៩៧៤ ៩៧៨ / ០៨៨ ៧ ០៩៩ ០៨៨ បានទូរស័ព្ទមកប្រាប់យើងខ្ញុំ ឱ្យប្រគល់ប្រាក់ម្នាក់ៗ ចំនួន ១៦០$ ទៀត សម្រាប់ធ្វើលិខិតឆ្លងដែន ។ ពេលនោះ ដោយមានការសង្ស័យ យើងខ្ញុំក៏បានទៅជួប ថ្នាក់ដឹកនាំ នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ទើបបញ្ជាក់បានថា ក្រុមហ៊ុនខាងលើពុំមានអាជ្ញាប័ណ្ណអនុញ្ញាតឱ្យធ្វើការបញ្ជូនកម្មសិក្សាការី ទៅធ្វើការនៅប្រទេសជប៉ុនទេ ។ ដូច្នេះយើងខ្ញុំសន្និដ្ឋានថា នាយកក្រុមហ៊ុន និងតំណាងក្រុមហ៊ុនខាងលើ មានចេតនាទុច្ចរិត ឆបោកយើងខ្ញុំ ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម ឧត្តមសេនីយ៍ឯក ប្រធាននាយកដ្ឋាន** មេត្តាជួយស្រាវជ្រាវ និងមានវិធានការ ចំពោះជនទាំងនោះ តាមច្បាប់ជាធរមាន ។

សូម **ឯកឧត្តម ឧត្តមសេនីយ៍ឯក** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី 08 ខែ 06 ឆ្នាំ២០១៧

ស្នាមមេដៃស្ដាំ

អែមនឿន

DV0030

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

THE PRESIDENT TELEGO COMPANY

LA NE CENTER JAPANS AGENCY

## វិក័យប័ត្រ

-ខ្ញុំបាទ /នាងខ្ញុំឈ្មោះ ម៉េង ឆេង សំណាង ភេទ ប ស្ម័គ្រចិត្តបង់ប្រាក់ដើម្បីដំណើរការឯកសារពាក់ព័ន្ធផ្សេងៗដូចជា:

1. បង់សំរាប់ធ្វើតេស្តឈាម ចំនួន 50$ ខ្ទះ:
2. បង់សំរាប់បកប្រែឯកសារ -អត្តសញ្ញាណប័ណ្ណ -សំបុត្រកំណើត -សៀវភៅគ្រួសារ -សៀវភៅស្នាក់នៅជាភាសាជប៉ុន និងភាសាអង់គ្លេស ចំនួន 30$ ខ្ទះ:

ដើម្បីទៅធ្វើការដោយស្របច្បាប់នៅប្រទេសជប៉ុនដោយគ្មានការបង្ខិតបង្ខំឡើយ។

-ខ្ញុំបាទ /នាងខ្ញុំសូមសន្យាថានឹងរង់ចាំធ្វើដំណើរនៅពេលដែលឯកសារត្រូវបានបំពេញរួចរាល់។

លេខទូរស័ព្ទ 069724276

បញ្ជាក់: ប្រាក់បង់ហើយមិនអាចដកវិញបានទេ។ * បើពិនិត្យឈាមទៅមានមេរោគអេដស៍និងប្រគល់ប្រាក់វិញគ្រប់ចំនួន។

ធ្វើនៅភ្នំពេញ ថ្ងៃទី 21 ខែ 04 ឆ្នាំ2017

ស្នាមមេដៃសាម៉ីខ្លួន

ម៉េង សំណាង

ហត្ថលេខាតំណាងក្រុមហ៊ុន

ម៉ៃ

3. ចិញ្ចឹមសត្វ

DV 0031

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

THE PRESIDENT TELEGO COMPANY
LA NÉ CENTER JAPANS AGENCY

**ភិក័យប័ត្រ**

-ខ្ញុំបាទ /នាងខ្ញុំឈ្មោះ ស៊ៀន ចាន់ន ភេទ ស្រី ស្ម័គ្រចិត្តបង់ប្រាក់ដើម្បីដំណើរការឯកសារពាក់ព័ន្ធផ្សេងៗដូចជា:

1. បង់សំរាប់ធ្វើតេស្តឈាម ចំនួន 50$ ខ្ទះ

2. បង់សំរាប់បកប្រែឯកសារ -អត្តសញ្ញាណប័ណ្ណ -សំបុត្រកំណើត -សៀវភៅគ្រួសារ -សៀវភៅស្នាក់នៅជាភាសាជប៉ុន និងភាសាអង់គ្លេស ចំនួន 30$ ខ្ទះ

ដើម្បីទៅធ្វើការដោយស្របច្បាប់នៅប្រទេសជប៉ុនដោយគ្មានការបង្ខិតបង្ខំឡើយ។

-ខ្ញុំបាទ /នាងខ្ញុំសូមសន្យាថានឹងរង់ចាំធ្វើដំណើរនៅពេលដែលឯកសារត្រូវបានបំពេញរួចរាល់។

លេខទូរស័ព្ទ 096 84 98 932

បញ្ជាក់:ប្រាក់បង់ហើយមិនអាចដកវិញបានទេ។ * បើពិនិត្យឈាមទៅមានមេរោគអេដស៍និងប្រគល់ប្រាក់វិញគ្រប់ចំនួន។

ធ្វើនៅភ្នំពេញ ថ្ងៃទី 21 ខែ 04 ឆ្នាំ2017

ស្នាមមេដៃសាមីខ្លួន

ស៊ៀន ចាន់ន

ហត្ថលេខាតំណាងក្រុមហ៊ុន

3. ចិញ្ចឹមសត

DV 0032

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

THE PRESIDENT TELEGO COMPANY
LA NE CENTER JAPANS AGENCY

### វិក័យប័ត្រ

-ខ្ញុំបាទ /នាងខ្ញុំឈ្មោះ អែម ឡឿន ភេទ ស ស្ម័គ្រចិត្តបង់ប្រាក់ដើម្បីដំណើរការឯកសារពាក់ព័ន្ធផ្សេងៗដូចជា:

1. បង់សំរាប់ធ្វើតេស្តឈាម ចំនួន 50$ ខ្ទះ:

2. បង់សំរាប់បកប្រែឯកសារ -អត្តសញ្ញាណប័ណ្ណ -សំបុត្រកំណើត -សៀវភៅគ្រួសារ -សៀវភៅស្នាក់នៅជាភាសាជប៉ុន និង ភាសាអង់គ្លេស ចំនួន 30$ ខ្ទះ:

ដើម្បីទៅធ្វើការដោយស្របច្បាប់នៅប្រទេសជប៉ុនដោយគ្មានការបង្ខិតបង្ខំឡើយ។

-ខ្ញុំបាទ /នាងខ្ញុំសូមសន្យាថានឹងរង់ចាំធ្វើដំណើរនៅពេលដែលឯកសារត្រូវបានបំពេញរួចរាល់។

លេខទូរស័ព្ទ 087 78 67 51

បញ្ជាក់:ប្រាក់បង់ហើយមិនអាចដកវិញបានទេ។ * បើពិនិត្យឈាមទៅមានមេរោគអេដស៍និងប្រគល់ប្រាក់វិញគ្រប់ចំនួន។

ធ្វើនៅភ្នំពេញ ថ្ងៃទី 21 ខែ 04 ឆ្នាំ2017

ស្នាមមេដៃសាមីខ្លួន អែម ឡឿន

ហត្ថលេខាតំណាងក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## បញ្ជីឈ្មោះទីភ្នាក់ងារជ្រើសរើសឯកជន ដែលបានទទួលការអនុញ្ញាតពី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបរទេស

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋខ្មែរ និង សាធារណជនទាំងអស់ឱ្យបានជ្រាបថា ដើម្បីការពារផលប្រយោជន៍ដល់ប្រជាពលរដ្ឋខ្មែរ ដែលមានបំណងចង់ទៅធ្វើការនៅបរទេសដោយស្របច្បាប់ ឬការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្រសួងសូមជូនដំណឹងអំពីទីភ្នាក់ងារជ្រើសរើសឯកជន ដែលទទួលការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និង គ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបរទេស ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះក្រុមហ៊ុន | ថៃ | ម៉ាឡេស៊ី | ជប៉ុន | លេខទូរស័ព្ទ |
|---|---|---|---|---|---|
| 1 | 168 Manpower Supply CO., LTD. | ✓ | ✓ | ✓ | 092 222 807 / 097 222 2807 / 010 222 807 |
| 2 | A.P.T.S.E & C (Cambodia) Resources CO., LTD. | ✓ | ✓ | ✓ | 023 635 3030 / 097 777 7468 / 012 439 776 |
| 3 | Anny Rita Best Manpower CO., LTD. | ✓ | ✓ | ✓ | 069 234 519 / 096 234 511 / 069 467 777 |
| 4 | Asian Human Support (Cambodia) CO., LTD. | | | ✓ | 077 577 574 / 023 577 574 |
| 5 | AGRI- FARMARS (CAMBODIA) CO., LTD. | | | ✓ | 012 722 325 |
| 6 | Axel Asia Human Resources CO., LTD. | | | ✓ | 012336847 / 016 888 747 / 088 713 0112 |
| 7 | B.S.R.O Best Manpower CO., LTD. | ✓ | ✓ | ✓ | 097 888 5581 / 096 294 7777 |
| 8 | Big Bi Imex Group CO., LTD. | ✓ | ✓ | ✓ | 015592225 / 097 3333 320 / 012 592 225 |
| 9 | BRIDGE JC CO., LTD. | | | ✓ | 070 418 742 / 097 888 3700 / 098 888 376 |
| 10 | CAM Human Capital CO., LTD. | ✓ | ✓ | ✓ | 012 616 161 |
| 11 | C A T M Asia Manpower Cooperation CO., LTD. | ✓ | ✓ | ✓ | 023 637 2333 / 061 699 999 / 097 336 9999 |
| 12 | C.J.T.T Trading CO., LTD. | ✓ | ✓ | ✓ | 023 650 4398 / 069 633 604 |
| 13 | C.L SUPPLY (CAMBODIA) CO., LTD. | ✓ | ✓ | ✓ | 088 424 9999 |
| 14 | C.T. Asia Labour CO., LTD. | ✓ | ✓ | ✓ | 089 848 409 / 077 709 280 / 077 886 762 |
| 15 | Cambodian Labour Supply PTY LTD. | ✓ | ✓ | ✓ | 017 666 938 / 012 370 374 / 017 666810 |
| 16 | CDM Trading Manpower CO., LTD. | ✓ | ✓ | ✓ | 023 630 3747 / 012 793 999 / 076 950 9999 |
| 17 | CECH (Cambodia) CO., LTD. | ✓ | ✓ | | 012 779205 / 093 630399 |
| 18 | Century (Cambodia) Manpower CO., LTD. | ✓ | ✓ | ✓ | 012 843 456 / 016 858 333 |
| 19 | Chhun Hong Manpower CO., LTD. | ✓ | ✓ | ✓ | 092 678 888 / 023 428 653 / 012 693 398 |



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

| | | | | | |
|---|---|---|---|---|---|
| 20 | C-Pro CO., LTD. | ✓ | | ✓ | 016 230 876 / 023 211 398 |
| 21 | Dream Manpower (Cambodia) CO., LTD. | ✓ | ✓ | ✓ | 070 577 211 / 077 947 484 / 017 726 281 |
| 22 | ELITE MANPOWER AGENCY CO., LTD. | ✓ | ✓ | ✓ | 017 693 777 / 088 688 9999 |
| 23 | FASTUP(Cambodia) CO., LTD. | ✓ | ✓ | ✓ | 089 450 656 / 081 882 600 / 092 285 6748 |
| 24 | Formis Manpower CO., LTD. | | ✓ | | 023 666 5222 / 012 707 787 |
| 25 | G P G C International PTE., LTD. | ✓ | ✓ | ✓ | 010 773 250 / 088 877 3965 / 086 650 339 |
| 26 | GALA TOKYO Manpower CO., LTD. | | | ✓ | 017 786 300 / 010 334 555 |
| 27 | Global Employment Service (Cambodia) CO., LTD. | | | ✓ | 023 966 778 / 012 443 888 |
| 28 | Growing Power CO., LTD. | ✓ | | ✓ | 012 472 140 / 070 252 971 / 016 609 539 |
| 29 | HIRAYAMA CO., LTD. | | | ✓ | 011 560 293 |
| 30 | Huaning International Development CO., LTD. | | | ✓ | 012 752 976 / 097 779 2079 / 098 402 404 |
| 31 | Human Power CO., LTD. | ✓ | ✓ | ✓ | 012 775 277 / 012 266 996 / 011 333 998 |
| 32 | Human Resource Development CO., LTD. | ✓ | ✓ | | 023 638 8377 / 088 999 9744 / 012 525 631 |
| 33 | I I S Company LTD. | ✓ | ✓ | ✓ | 016 891 912 / 077 855 552 / 088 755 5525 |
| 34 | I.G. Consultant CO., LTD. | ✓ | ✓ | ✓ | 023 966 168 / 015 811 111 / 077 811 111 |
| 35 | JNN International Economic and Technical Coopeartion CO., LTD. | | | ✓ | 070 402 613 / 010 215 791 / 088 825 4072 |
| 36 | Job Asian (Cambodia) CO., LTD. | ✓ | ✓ | ✓ | 097 535 3537 |
| 37 | Kakehashi International & Business CO., LTD. | | | ✓ | 016 676 721 |
| 38 | Kei Kei (Cambodia) Human Resource CO., LTD. | ✓ | ✓ | ✓ | 023995074 / 012287655 / 070 553 893 |
| 39 | Kizuna HR-Asia CO., LTD. | | | ✓ | 023 224 606 / 012 256 985 |
| 40 | Kobe Human Service (Cambodia) CO., LTD. | ✓ | | ✓ | 023 640 8666 / 086 955 556 |
| 41 | LIMINA CO., LTD. | | | ✓ | 016 474763 / 017 727 409 |
| 42 | Malcam CO., LTD. | ✓ | ✓ | | 097 706 1097 |
| 43 | Master Cam Human Resource CO., LTD. | ✓ | ✓ | | 023 726 301 / 023 726 201 / 070 496 924 |
| 44 | MEAS SOVANN MEALEAKE MANPOWER CO., LTD. | ✓ | ✓ | ✓ | 092 231 111 / 097 888 3888 |
| 45 | MEIHO APHIVAT CO., LTD. | | | ✓ | 092 949 600 / 010 277 900 |
| 46 | Mey Yorn Service CO., LTD. | ✓ | ✓ | ✓ | 012 255 955 / 023 637 6388 / 017 366 626 |
| 47 | NATH THAKNAN MANPOWER CO., LTD. | ✓ | ✓ | ✓ | 097 336 9999 / 012 533 912 |
| 48 | N.A.S Manpower CO., LTD. | ✓ | ✓ | ✓ | 092 555 587 / 088 217 9393 |
| 49 | NGO ALC and JCIA | | | ✓ | 023 555 2936 / 023 555 2937 / 016 668 349 |
| 50 | NGO GCHCC | | | ✓ | 012 511 333 / 096 536 5268 / 017 908 288 |
| 51 | NICAM CO., LTD. | | | ✓ | 011 419 088 |
| 52 | P I T T Cambodia CO., LTD. | ✓ | ✓ | ✓ | 012 378 486 / 012 723 366 |
| 53 | Philimore Cambodia CO., LTD. | ✓ | ✓ | ✓ | 097 807 7120 / 012 600 997 |
| 54 | Phnom Penh Labour Supply CO., LTD. | ✓ | ✓ | ✓ | 012 216 000 / 010 216 000 / 012 995 666 |
| 55 | P.M. PROFESSIONAL MANPOWER CO., LTD. | ✓ | ✓ | ✓ | 088 787 7779 / 062 803 8076 / 098 962 716 |
| 56 | Praseth Hathakpolkor(Cambodia) CO., LTD. | | | ✓ | 098 988 886 / 097 6 626 002 |
| 57 | PRO CAST (Cambodia) CO., LTD. | | | ✓ | 078 779 715 |
| 58 | RRD MANPOWER CO., LTD. | ✓ | ✓ | ✓ | 012 655 111 |
| 59 | SKMM Investment Group CO., LTD. | ✓ | ✓ | ✓ | 088 888 7791 / 012 969 9999 |
| 60 | Sok Chamnol CO., LTD. | ✓ | ✓ | ✓ | 088 666 6559 |
| 61 | Sok Leap Metrey CO., LTD. | ✓ | ✓ | ✓ | 015 301 111 / 097 807 7121 |
| 62 | STP International Cambodia Public CO., LTD. | ✓ | | | 023 993 922 / 016 282 442 / 092 363 168 |
| 63 | STAND POWER CORPORATION LIMITED. | | | ✓ | 077 868 868 |
| 64 | Success Manpower Services CO., LTD. | ✓ | ✓ | ✓ | 023 969 709 / 099 799 799 / 097 9999 849 |
| 65 | TAK TAK CO., LTD. | | | ✓ | 087 737 777 / 081 990 077 |

| | | | | | |
|---|---|---|---|---|---|
| 66 | TOMORROW HR (CAMBODIA) CO., LTD. | | | | 069 553 317 / 012 253 633 |
| 67 | Top Manpower CO., LTD. | ✓ | ✓ | ✓ | 097 932 2322 / 012 922 322 / 081 990 077 |
| 68 | Touch Manak Manpower Supply CO., LTD. | ✓ | ✓ | ✓ | 097792 88 00 / 097 597 8888 |
| 69 | Ung Rithy Group CO., LTD. | ✓ | ✓ | ✓ | 097 727 3007 / 012 686 996 |
| 70 | Unicorn Manpower CO., LTD. | ✓ | ✓ | ✓ | 071 572 3457 / 023 636 533 / 097 520 5006 |
| 71 | Win-Win Manpower Service CO., LTD. | ✓ | ✓ | ✓ | 096 7070 674 |
| 72 | YOTA MANPOWER SUPPLY CO., LTD. | | | ✓ | 089 370 750 / 097 319 1020 |
| 73 | YAKUSHIKAI (CAMBODIA) CO., LTD. | ✓ | ✓ | ✓ | 012 89 2222 / 089 855 001 |
| 74 | 57 Goal Manpower CO., LTD. | ✓ | ✓ | ✓ | 081 6666 53 / 071 666 9596 |
| 75 | AJC CO., LTD. | | | ✓ | 012 333 113 / 012 717 192 / 016 777 112 |
| 76 | I-CEP Phnom Penh CO., LTD. | | | ✓ | 097 295 9699 |
| 77 | The Seaboard Cambodian Development Construction CO., LTD. | ✓ | ✓ | ✓ | 012 849 566 |

*(គេហទំព័រ www.mltv.gov.kh)*

ជាមួយគ្នានេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសូមអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋ និងសាធារណជនទាំងអស់ មេត្តាប្រុងប្រយ័ត្នចំពោះជនខិលខូច ជនឆ្លៀតឱកាស ជាពិសេសក្រុមហ៊ុន ឬអង្គការមួយចំនួនមិនមានឈ្មោះក្នុងតារាងខាងលើនេះ ហើយធ្វើសកម្មភាពបោកប្រាស់ក្រោមរូបភាពជ្រើសរើស បណ្តុះបណ្តាល បញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសដោយខុសច្បាប់។ ក្នុងករណីបងប្អូនប្រជាពលរដ្ឋខ្មែរ និងសាធារណជនបានជួបដូចករណីខាងលើនេះ សូមផ្តល់ព័ត៌មានមកនាយកដ្ឋានមុខរបរ និង ហត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈទូរស័ព្ទលេខ ០២៣៨៨០៤៧៤ / ០១១៨៩៨៩១២ / ០៧៧២៧៤២៤៧ / ០៩៨៧៦៥៤១១ ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្តទាំង២៥។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបងប្អូនប្រជាពលរដ្ឋខ្មែរ និងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៧